بسم الله الرحمن الرحيم

# តើគម្ពីរគួរអានជាអ្វី?

គម្ពីរគួរអាន គឺជាបន្ទូលរបស់អល់ឡោះជាព្រះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់
និងជាព្រះជាម្ចាស់ដែលបានបង្កើតពួកគេ។ ទ្រង់បានបញ្ចុះវាទៅកាន់ព្យាការី និងជាអ្នកនាំសារចុងក្រោយបង្អស់
មូហាំម៉ាត់ សអវ ដើម្បីបញ្ជាក់ដល់មនុស្សលោកពីគោលបំណងនៃការបង្កើតពួកគេ
និងដើម្បីចង្អុលបង្ហាញពួកគេទៅកាន់អ្វីដែលនាំមកនូវសុភមង្គលដល់ពួកគេទាំងក្នុងលោកិយ
និងបរលោកខាងមុខ ក៏ដូចជាដើម្បីសង្គ្រោះមនុស្សលោកពីភាពអពមង្គលដ៏អស់កល្បជានិច្ចក្រោយពេលស្លាប់។
វាគឺជាព្រះគម្ពីរចុងក្រោយបង្អស់របស់ព្រះជាម្ចាស់ដែលត្រូវបានបញ្ចុះមកដើម្បីធ្វើការបញ្ជាក់ទៅលើព្រះគម្ពីរទាំង
នោះ និងនិរាករណ៍ចោលនូវច្បាប់បញ្ញត្តិដែលមានចែងក្នុងព្រះគម្ពីរមុនៗទាំងនោះផងដែរ។
គម្ពីរគួរអាន គឺជាសញ្ញាភស្តុតាង និងជាអច្ឆរិយភាពដ៏អមតៈ។
វាគឺជាភស្តុតាងនៃភាពជាព្យាការីនៃអ្នកនាំសាររបស់អល់ឡោះ មូហាំម៉ាត់ សអវ។
អល់ឡោះជាម្ចាស់ទ្រង់បានប្រកាសឲ្យពួកជិន
និងមនុស្សលោកឲ្យប្រកួតប្រជែងនឹងគម្ពីរគួរអានដោយនាំមកនូវគម្ពីរមួយដែលដូចនឹងគម្ពីរគួរអាននេះ
ឬសូម្បីតែមួយជំពូកដែលដូចវា។ ក៏ប៉ុន្តែពួកគេអសមត្ថភាពក្នុងការធ្វើដូច្នោះ។
គម្ពីរគួរអានគ្មានការកែប្រែ ឬផ្លាស់ប្តូរនោះឡើយចាប់ពីវាត្រូវបានបញ្ចុះមកតាំងពីជាង១៤០០ឆ្នាំមុន
ហើយវានៅតែត្រូវបានគេថែរក្សាជាភាសាអារ៉ាប់ ដែលជាភាសាដើមដែលគេបញ្ចុះគម្ពីរនេះមក
ខណៈដែលអល់ឡោះជាម្ចាស់ ទ្រង់បានធានាថែរក្សាគម្ពីរនេះ រហូតដល់អវសាននៃផែនដី។
គម្ពីរគួរអាន គឺជាប្រភពមូលដ្ឋាននៃសាសនាឥស្លាម និងជាធម្មនុញ្ញដែលរៀបចំសណ្តាប់ធ្នាប់
និងវិធីជួយទៅលើការរស់នៅរបស់មនុស្សនៅគ្រប់សម័យកាល និងគ្រប់ទីកន្លែង។
គម្ពីរគួរអានអំពាវនាវមនុស្សទៅកាន់ការគោរពសក្ការៈចំពោះព្រះអាទិទេពជាអម្ចាស់ដែលជាអ្នកបង្កើតតែមួយអ
ង្គគត់។ វាបញ្ជាក់នូវអ្វីដែលមនុស្សលោកត្រូវការដើម្បីស្គាល់ព្រះជាម្ចាស់ និងសាសនារបស់គេ
ព្រមទាំងបញ្ជាក់ពីការចាប់ផ្តើមនៃការបង្កើតចក្រវាឡ ដំណាក់កាលនៃការបង្កើតមនុស្ស
ប្រាប់ពីរឿងរ៉ាវអាថ៌កំបាំងទាំងក្នុងអតីតកាល និងអនាគតកាល
និងមានការរៀបរាប់ប្រាប់ពីប្រវត្តិរឿងរ៉ាវរបស់បណ្តាព្យាការីជំនាន់មុនៗ ថាតើទ្រង់បានសង្គ្រោះពួកគាត់
និងបំផ្លាញសត្រូវរបស់ពួកគាត់យ៉ាងដូចម្តេច។ នៅក្នុងគម្ពីរគួរអានផងដែរ
គឺផ្តុកទៅដោយមូលដ្ឋានគ្រឹះនៃការគោរពសក្ការៈ ការទំនាក់ទំនង
និងការអំពាវនាវទៅកាន់សីលធម៌ដែលគេកោតសរសើរ ព្រមទាំងព្រមានពីភាពអសីលធម៌ដែលគួរឲ្យស្អប់ខ្ពើម
ក៏ដូចជាកន្លែងដែលត្រូវវិលត្រឡប់នៅថ្ងៃបរលោក អាចជាឋានសួគ៌ដែលជាលំនៅឋានសម្រាប់អ្នកមានជំនឿ
ឬអាចជាឋាននរកដែលជាលំនៅឋានសម្រាប់ពួកដែលបំពាន គ្មានជំនឿ។
ដោយឃើញពីសារៈសំខាន់នៃគម្ពីរដ៏ឧត្តុង្គឧត្តមនេះដែលអល់ឡោះបានបញ្ចុះជាភាសាអារ៉ាប់
ហើយទ្រង់បានបង្គាប់ប្រើឲ្យធ្វើការផ្សព្វផ្សាយវាទៅកាន់មនុស្សលោក
យើងខ្ញុំមានក្តីសោមនស្សរីករាយសូមផ្តល់ជូនលោកអ្នកអានជាទីមេត្រីនូវគម្ពីរគួរអានដែលត្រូវបានប្រែសម្រួល
ជាខេមរភាសាដើម្បីជួយសម្រួលដល់ការយល់ពីអត្ថន័យរបស់វា
និងដើម្បីសម្រេចបាននូវការផ្សព្វផ្សាយគម្ពីរនេះ។ ក្រុមការងារបានខិតខំប្រឹងប្រែងក្នុងការឈ្វេងយល់
និងបកប្រែអត្ថន័យរបស់វា ទោះជាបានដឹងច្បាស់ប្រាកដរួចទៅហើយក៏ដោយថា
ទោះបីជាខិតខំធ្វើការប្រែសម្រួលយ៉ាងលម្អិតផ្ចិតផ្ចង់យ៉ាងណាក៏ដោយ
ក៏ភាពខ្វះចន្លោះនៅតែក្នុងការឈានទៅដល់អត្ថន័យដើមពិតប្រាកដដែលមាននៅក្នុងគម្ពីរគួរអានដ៏អច្ឆរិយៈនេះ
ដែលវាលើសពីសមត្ថភាពរបស់មនុស្សឈានដល់។
ជនណាដែលមានបំណងចង់ដឹងបន្ថែមពីធាតុពិតដែលបាននាំមកដោយគម្ពីរគួរអាន
យើងខ្ញុំសូមណែនាំឲ្យរូបគេសិក្សាភាសាអារ៉ាប់ដែលជាភាសាដើមដែលគេបញ្ចុះវាមក។
وسلام على المرسلين، والحمد لله رب العالمين

សព្វវចនាធិប្បាយគម្ពីរអាល់គួរអានុលការីម
លោកអ្នកអាចចូលទៅកាន់អត្ថន័យនៃគម្ពីរគួរអានជាខេមរភាសាដោយស្កេន QR Code
ជាមួយនឹងកាមេរ៉ាទូរសព្ទ។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយចំពោះការផ្តល់យោបល់
និងការរិះគន់ក្នុងន័យស្ថាបនារបស់អស់លោកអ្នកដើម្បីអភិវឌ្ឍន៍ការបកប្រែតាមរយៈ "បង្អួចកំណត់ចំណាំ"
ដែលមាននៅពីមុខវាក្យខណ្ឌនីមួយៗនៅលើគេហទំព័រ សព្វវចនាធិប្បាយគម្ពីរអាល់គួរអានុលការីមៈ
(www.quranenc.com)។ ប្រសិនបើលោកអ្នកមានបំណងទាក់ទងមកកាន់យើងខ្ញុំ
លោកអ្នកអាចផ្ញើអ៊ីមែលមកកាន់យើងខ្ញុំតាមរយៈ៖ info@quranenc.com

بسم الله الرحمن الرحيم

តើគម្ពីរគួរអានជាអ្វី?